# សារមន្ទីរវិទ្យាសាស្ត្រសមុទ្រ

ផ្នែកទីមួយ (លេខ២នៅក្នុងផែនទីការតាំងពិព៌ណ) ចាត់តាំងពិព៌ណអបអរសាទរព្រះបាទសម្តេចភូមិផុន អាឌុនយាតេជទាក់ទងជាមួយនិងព្រះរាជភារកិច្ចផ្នែកស្តារ អភិរក្សធនធានធម្មជាតិ និងផ្នែកវិទ្យាសាស្ត្រនេសាទ





ផ្នែកទីពីរ រៀបចំ តាំងពិព៌ណទាក់ទងនិងរឿងរាវរបស់សមុទ្រ ប្រព័ន្ធអេកូឡូស៊ីនិងវត្ថុមានជីវិតដែលរស់នៅក្នុងសមុទ្រ រួមទាំងសារៈសំខាន់ដល់មនុស្សដូចតទៅនេះ

១) ការតាំងពិព៌ណរឿងរាវរបស់អាណាចក្រវត្ថុមានជីវិតក្នុងសមុទ្រ ដោយផ្តល់ចំនណះដឹងចាប់តាំងពីវត្ថុមានជីវិតខ្នាតតូចៗដែលរស់នៅក្នុងសមុទ្រ គឺប្លង់តុងដែលមានតួនាទីយ៉ាងសំខាន់របស់ចរន្តចង្វាក់អាហារក្នុងសមុទ្រ សារាយ និងស្មៅសមុទ្រ ពពុះទឹក សត្វដែលមានដងខ្លួនប្រហោង ដូចជាផ្កាថ្មផ្កាសមុទ្រ ជំពុលទឹកជាដើម។ សត្វជំពូកដង្កូវសមុទ្រ ដូចជា ដង្កូវរាងសំប៉ែត ដង្កូវរាងមូល ដង្កូវរាងវែង ជាដើម។ សត្វជំពូកគ្រុំ ដូចជា គ្រុំសំបកមួយ គ្រុំសំបកពីរ មឹកនិងគ្រុំប្រមោយដំរីជាដើម សត្វដែលមានថ្នាំងកង់ក្នុងសមុទ្រដូចជា ក្តាម បង្កង និងបន្ទាទូកសមុទ្រជាដើម។ សត្វជំពូកខវ៌ដេតក្នុងសមុទ្រដូចជាជន្លេនសមុទ្រ អាហ្វិសអកស្ស៊ែត និងសត្វសមុទ្រដែលមានឆ្អឹងខ្នងប្រភេទផ្សេងៗ មានដូចជាត្រីសមុទ្រ ផ្សោតជ្រូកទឹក និងក្រពើទឹកប្រៃ រួមទាំងរឿងរាវរបស់សមុទ្រតាំងពីបូរាណកាលជាដើម








២) ការតាំងពិពិណរឿងរាវរបស់សមុទ្រ និងប្រពន្ធ័អេកូឡូស៊ីក្នុងសមុទ្រ ក្នុងផ្នែកនេះនឹងនិយាយរៀបរាប់អំពីការបែងចែកតំបន់សមុទ្រនិងប្រពន្ធ័អេកូឡូស៊ីផ្សេងៗក្នុងសមុទ្រ រួមទាំងរុក្ខជាតិនិងសត្វសមុទ្រដែលរស់នៅក្នុងប្រពន្ធ័អេកូឡូស៊ីនិមួយៗ ដោយចាប់ផ្តើមពីប្រពន្ធ័អេកូឡូស៊ីព្រៃរនាម ប្រពន្ធ័អេកូឡូស៊ីឆ្នេរថ្ម ប្រពន្ធ័អេកូឡូស៊ីឆ្នេរខ្សាច់និងប្រពន្ធ័អេកូឡូស៊ីឆ្នេរភក់ ប្រពន្ធ័អេកូឡូស៊ីតំបន់ផ្កាថ្មជាដើម។




៣) ការតាំងពិពិណទាក់ទងនឹងសារៈសំខាន់របស់សមុទ្រដែលមានចំពោះមនុស្ស ជាផ្នែកដែលចាត់តាំងពិពិណទាក់ទងនឹងសារៈសំខាន់ចំពោះមនុស្សដូចជា ជាប្រភពសំរាប់ធ្វើនេសាទដោយប្រើឧបករណ៍នេសាទសមុទ្រដូចជា ផៃនិងទូកនេសាទសមុទ្រប្រភេទផ្សេងៗជាផ្លូវប្រកបការជួញដូរ ការធ្វើដំណើរទំនាក់ទំនងរបស់មនុស្សចាប់តាំងពីអតីតរហូតដល់បច្ចុប្បន្នដែលត្រូវជួបប្រទះនឹងឧបសគ្គនានាពីរលក ខ្យល់និងព្យុះ បានធ្វើអោយទូកលិចកើតជារឿរាវរបស់ការរុករកនិងសិក្សាបូរាណវិទ្យាបាតសមុទ្រ ជាដើម។





៤) បន្ទប់សារៈមន្ទីរសំនបកគ្រុំ និងការវិវត្តរបស់គ្រុំ ក្នុងបន្ទប់នេះនឹងចាត់តាំងពិពិណទាក់ទងនឹងសំបកគ្រុំដែលជួបប្រទះក្នុងសមុទ្រ ក្រុមនិមួយៗមានដូចជា សង្កើចសមុទ្រ គ្រុំសំបកមួយ គ្រុំសំបកពីរ គ្រុំប្រមោយដំរីនិងគ្រុំភ្លុកដំរីជាដើម។ រួមទាំងការចាត់តាំងពិពិណផ្តល់ចំណេះដឹងទាក់ទងនឹងគ្រុំក្រុមនិមួយៗ ការវិវត្តរបស់គ្រុំពីអតីតរហូតដល់បច្ចុប្បន្ននិងការបែងចែកក្រុមរបស់គ្រុំដែលមាននៅក្នុងពិភពលោក។



